# ព្រះចក្រសំវរនៅក្នុងសង្គមខ្មែរ

ទោះបីជាព្រះពុទ្ធសាសនាវជ្រយាន ហូរចូលមកក្នុងសង្គមខ្មែរនៅតំបន់អង្គរក្នុងស.វ.ទី១០ ក៏ដោយ សាសនានេះក៏បានរីកសុះសាយទៅដល់តំបន់ឆ្ងាយពីអង្គរដែរ។ ជាក់ស្តែង នៅស.វ.ទី១១ តំបន់មួយដែលនៅមិនឆ្ងាយពីជួរភ្នំដងរែក ម្តុំប្រាសាទភិមាយ ប្រទេសថៃបច្ចុប្បន្ន ដែលគេស្គាល់ឈ្មោះថា សន្តតិវង្ស "មហីធរបុរ" ក៏នៅតែបន្តអនុវត្តន៍ព្រះពុទ្ធសាសនានិកាយវជ្រយានដដែល។ ក្នុងនោះ គេសង្កេតឃើញថា មានព្រះមហាក្សត្រសំខាន់ៗចំនួនពីរដែលកាន់ព្រះពុទ្ធសាសនានិកាយវជ្រយាន និងព្រះមហាក្សត្រសំខាន់មួយអង្គទៀតកាន់ព្រះព្រហ្មញ្ញសាសនាលទ្ធិព្រះវិស្ណុ (វៃស្ណវ) ហើយព្រាហ្មណ៍ដែលសំខាន់ចំពោះមហាក្សត្រទាំងបីអង្គគឺ ព្រះរាជគ្រូស្រីទិវាករបណ្ឌិត។ ម្ល៉ោះហើយ ទើបគេឃើញមានចម្លាក់ទេពជាមួយចំនួនទាក់ទងនឹងព្រះពុទ្ធសាសនានិកាយវជ្រយាននៅប្រាសាទភិមាយ។ នៅក្នុងអត្ថបទខ្លីនេះ យើងសូមលើកយកទេពមួយមកអធិប្បាយដោយសង្ខេបគឺ "ចក្រសំវរ" ឬហៅមួយបែបទៀតថា "សំវរ" ដែលគេឃើញវត្តមាននៅលើផ្តែរទ្វារប្រាសាទភិមាយ។

ចក្រសំវរ (Cakrasaṃvara) គឺជាទេពដ៏ខ្លង់ខ្លស់មួយនៅក្នុងទម្រង់ហេរុក (ទម្រង់កាច) នៃលទ្ធិព្រះពុទ្ធសាសនាបែបតន្ត្រដែលកើតឡើងនៅរវាងចុងស.វ.ទី៨ ដើមស.វ.ទី៩ នៅស្រុកឥណ្ឌា (រូបលេខ១) ហើយបន្តរីកសាយភាយទៅកាន់តំបន់ទីបេ និងអាស៊ីអាគ្នេយ៍។[១] ចក្រ មានន័យថា "វដ្ត" រីឯ "សំវរ" ជាកិរិយាស័ព្ទអាចប្រែបានថា "ចង", "បិទបាំង", "លាក់", ហើយក៏អាចប្រែថា "សច្ចា" ឬ "ជម្រក" បានទៀតផង។[២] នៅតំបន់ទីបេ គេចាត់ទុកចក្រសំវរ គឺជាផ្នែកមួយនៃយីទុម ឬអាទិទេពសមាធិនៃសាលាសម៌ ដែលភាគច្រើនគេបង្ហាញចក្រសំវរមានព្រះកាយពណ៌ខៀវ ព្រះភក្ត្រ៤ ព្រះហស្ត១២ ហើយតែងឈរនៅកៀកឱបព្រះមហេសីរបស់ទ្រង់ព្រះនាម វជ្រវារាហី (ទេពនៃប្រាជ្ញា) (រូបលេខ២)។[៣] ទម្រង់របស់ចក្រសំវរ ដែលមានទម្រង់របៀបកាច (ហេរុក) មានលក្ខណៈមិនសូវខុសគ្នាពីព្រហ្មញ្ញសាសនានិកាយព្រះឥសូរទេ ព្រោះនៅក្នុងលទ្ធិព្រះឥសូរក៏មានទម្រង់កាចដូចគ្នា ជាពិសេសគឺទម្រង់ដែលព្រះឥសូរជាភៃរវឬមហាកាល។ ភាគច្រើន ភៃរវនៃព្រហ្មញ្ញសាសនាគេបង្ហាញរូបភាពជាទេពមានព្រះនេត្រក្រឡោត ព្រះនេត្រទីបីនៅលើថ្ងាស ចំណិតព្រះចន្ទ្រនៅលើផ្នួងព្រះកេស សម្លៀកបំពាក់គ្រងដោយស្បែកខ្លា ព្រះភក្ត្រច្រើន ព្រះហស្តច្រើន កាន់ចានរូប

---

[១] Buswell & Lopez 2013: 162-163.

[២] Gray 2007: 35.

[៣] Ibid.

លលាដ៍ក្បាល នៅជុំវិញព្រះកាយមានលលាដ៍ក្បាលហូរស្រក់ឈាមធ្លាក់មកដី មានដំរីដ៏អាថ៌កំបាំងមួយតំណាងឱ្យការបំភាន់ភ្នែក កាត់ក្បាលព្រះព្រហ្ម មានពស់តំណាងឱ្យសរសៃព្រាហ្មណ៍ មានចង្កូមស្រួច លាបផេះពាញព្រះកាយ ហើយច្រើនគង់នៅក្នុងទីសក្ការបូជា។ ចំណែកនៅក្នុងព្រះពុទ្ធសាសនាបែបតន្ត្រ គេចាត់ទុក សំវរ គឺជាឧបករណ៍ដ៏សំខាន់ដែលបាននាំជាតុសំខាន់ៗរបស់លទ្ធិព្រះសិវ ចូលទៅក្នុងព្រះពុទ្ធសាសនា។[៤] ហេតុដូច្នេះហើយ ទើបគេឃើញការតុបតែងរបស់ចក្រសំវរ ឬទេពដែលមានទម្រង់កាចផ្សេងៗទៀតរបស់តន្ត្រ ដូចជា ហេវជ្រ ។ល។ តែងតែតុបតែងខ្លួនជាទម្រង់កាចដូចភៃរវដែរ។ គេកត់សម្គាល់ឃើញថា ជាទូទៅ ការបង្ហាញចក្រសំវរ គឺបង្ហាញឡើងក្នុងការរាំដូចហេវជ្រ ឬដូចព្រះឥស្វរដែរ ហើយក្បាច់រាំរបស់ចក្រសំវរ មានឈ្មោះថា "អធ៌បយ៌ង្ក" (ardhaparyaṅka) ដោយទ្រង់ឈររាំនៅលើម្កុដរបស់មារចំនួនពីរ និងនៅលើក្បាលដំរីមួយ។[៥]

នៅក្នុងសិល្បៈខ្មែរ ការបង្ហាញចម្លាក់ ឬបដិមាចក្រសំវរ មិនសូវសម្បូណ៌ដូចព្រះហេវជ្រឡើយ ពោល បើគិតជាចម្លាក់ថ្មគេឃើញច្បាស់លាស់ តែនៅលើផ្ដែរទ្វារច្រកចូលខាងកើតនៃប្រាសាទភិមាយមួយប៉ុណ្ណោះ (រូបលខ២៣)។ ចម្លាក់ចក្រសំវរនៅប្រាសាទភិមាយ បង្ហាញឡើងក្នុងរបៀបដែលទេពនេះផុសចេញពីដំរីដ៏អាថ៌កំបាំងមួយ (ក្បាលដំរីនៅខាងក្រោម កន្ទុយដំរីនៅលើព្រះសិររបស់ចក្រសំវរ) ក្នុងទម្រង់ព្រះបាទទាំងពីររបៀបឈររាំនៅលើមារចំនួនពីរនាក់ (ព្រះបាទខាងឆ្វេងដាក់ចុងព្រះបាទទៅក្រោមជាប់នឹងមារ រីឯព្រះបាទខាងស្ដាំដាក់លើកឡើងលើមកជាប់ជាមួយកែងព្រះបាទខាងឆ្វេងផុតពីដី)។ ចំណែក ព្រះភក្ត្រមានបួន ព្រះហស្តមានប្រាំបី (ព្រះហស្តចំនួន៦ ដាក់សន្ធឹងឡើងលើ រីឯព្រះហស្ត២ទៀតដាក់រាំត្រឹមដើមទ្រូង)។ នៅជុំវិញព្រះចក្រសំវរ មានរូបយោគិនី និងវិទ្យាធរឈររាំអម និងមានព្រះពុទ្ធពីរអង្គនៅខាងលើ។ ចម្លាក់នេះដែរ លោក Pia Conti យល់ថា ចម្លាក់នៅកណ្ដាលដែលយើងកំពុងពណ៌នាថាជាចក្រសំវរនេះ លោកគិតថាជារូបព្រះពុទ្ធ ហ៊ុមព័ទ្ធដោយជិនទាំងបួន គឺអក្សោភ្យ ក្នុងទម្រង់ព្រះពុទ្ធសាសនាបែប Esoteric ដែលមាននិយាយនៅក្នុងអត្ថបទ គុហយសមាជតន្ត្រ (guhyasamājatantra)។[៦] រូបចក្រសំវរនៅប្រាសាទភិមាយនេះ គេសន្និដ្ឋានថាឆ្លាក់នៅរជ្ជកាលព្រះបាទជ័យវរ្ម័នទី៦ ក្នុងរចនាបថ បាភួន។[៧] ចម្លាក់ចក្រសំវរនេះ មានទម្រង់ស្រដៀងរូបចម្លាក់ទេពរាំមួយនៅក្នុងសិល្បៈចាម (រូបលេខ២៤) ដែលលោក Peter Sharrock សង្ស័យថា អាចជារូបចក្រសំវរដែរ។ រូបចម្លាក់ថ្មមួយទៀត បង្ហាញអំពីព្រះ

---

[៤] Sharrock 2022: 133-139.

[៥] Ibid.

[៦] Conti 2014: 386; Szanto & Griffiths 2015: 370.

[៧] Sharrock 2022: 138-139.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ពុទ្ធមានព្រះហស្ត៤ ព្រះភក្ត្រ៤ មានកាយវិការកំពុងឈររាំនៅប្រាសាទបន្ទាយឆ្មារ គេមិនច្បាស់ថាជាទេពអ្វីឱ្យប្រាកដឡើយ។ ប៉ុន្តែ លោក Peter Sharrock យល់ថា ការបង្ហាញរូបរាំក្នុងទម្រង់កាចបែបនេះអាចជាការរាំរបស់ទម្រង់ហេរុកនៃតន្ត្រ ហើយក៏អាចជា ចក្រសំវរ ដែរ (រូបលេខ៥)។ ក្រៅពីនេះ មានរូបចក្រសំវរចំនួនតិចតួចទៀតដែលគេឆ្លាក់នៅលើសំរិទ្ធដែលយើងមិនបានយកមកបង្ហាញនាពេលនេះ។[៨]

ជារួមមក បើទោះបីរូបចម្លាក់ចក្រសំវរនៅក្នុងសង្គមខ្មែរសម័យបុរាណ ពុំមានចំនួនច្រើនដូចហេវជ្រក៏ដោយ ក៏បង្ហាញឱ្យឃើញថា ឥទ្ធិពលដែលខ្មែរទទួលយកព្រះពុទ្ធសាសនានិកាយវជ្រយានចាប់ពីស.វ.ទី១០ ដល់ទី១៣ ចាត់ទុកថាមានទំហំខ្លាំងក្លា។ ការបង្ហាញរូបចក្រសំវរតិចតួចនៅក្នុងសង្គមខ្មែរ អាចសបញ្ជាក់ឱ្យឃើញថា មនុស្សសម័យបុរាណពុំសូវនិយមរាប់អានទេពអង្គនេះ ឬក៏មានហេតុផលជាច្រើនទៀតដែលយើងមិនអាចដឹងបាន។ សព្វថ្ងៃ ការគោរពប្រណិប័តន៍ទេពអង្គនេះ និងនិកាយវជ្រយានទាំងមូលលែងមានទៀតហើយនៅក្នុងសង្គមខ្មែរ៕

## ឯកសារយោង


Buswell, R.J. & Lopez, D.S. Jr.

2013, *Princeton Dictionary of Buddhism.* Princton, NJ: Princeton University Press. pp. 162-163.

Conti, P.

2004, 'Tantric Buddhism at Prasat Hin Phimai: A new Reading of Its Iconographic Message', in Nicolas Revire and Stephen A. Murphy (eds), *Before Siam: Essays in Art and Archaeology,* pp. 374-395. Bangkok: River Books.

Gray, D.B.

2006, *The Cakrasaṃvara Tantra (The Discourse of Sri Heruka): Study and Annotated Translation.* New York: Columbia University Press.

Sharrock, P.

2022, 'Heruka-Maṇḍala across Maritime Asia', *Creative South,* Volume 1, London.

Szanto, P. & Griffiths, A.

2015, 'Sarvabuddhasamayogadakinijalasamvara', in *Brill's Ecycolopaedia of Buddhism,* Vol 1, *Literature and Languages,* pp. 367-372. Leiden: Brill.


[៨] Sharrock 2022: 139-141.

អត្ថបទដោយ៖ ម៉ង់ រ៉ាលី





រូបលេខ១-២៖ ចម្លាក់ចក្រសំវររកឃើញនៅតំបន់ Bihar ប្រទេសឥណ្ឌា និងរូបគំនូរចក្រសំវររកឃើញនៅតំបន់ទីបេ

(ប្រភព៖ https://en.wikipedia.org/wiki/Cakrasa%E1%B9%83vara_Tantra )





រូបលេខ៣៖ ចម្លាក់ចក្រសំវរនៅប្រាសាទភិមាយ រាំអមដោយយោគិនី និងវិទ្យារាជ (រូបថត៖ Conti 2014)

រូបលេខ៣.១៖ លម្អិតរូបទេពចក្រសំវរ នៅប្រាសាទភិមាយ (រូបថត៖ Sharrock 2022)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី





រូបលេខ២៨៖ ចម្លាក់ចក្រសំវរ (?) នៅប្រាសាទ Dương Long នៃសិល្បៈចាម (រូបថត៖ Anne-Valérie Schweyer)

រូបលេខ២៩៖ ចម្លាក់ចក្រសំវរ (?) នៅប្រាសាទបន្ទាយឆ្មារ (រូបថត៖ លឿង សុវណ្ណា)

អរិយធម៌ខ្មែរ KHMER CIVILIZATION